**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
លេខ ១៨៤០ សជណ.ររក.បអ

ភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេចទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថាៈ ចាប់ពីចុងខែ កុម្ភៈ ដល់ដើមខែ មីនា ឆ្នាំ ២០១៤ នេះ អគ្គិសនីកម្ពុជា នឹងធ្វើការផ្លាស់ប្តូរបរិក្ខារអគ្គិសនីមួយចំនួន នៅអនុស្ថានីយ៍អគ្គិសនីទី៦ ឧត្តុង្គ និងអនុស្ថានីយ៍អគ្គិសនីកំពង់ចាម ដែលធ្វើឲ្យមានការរអាក់រអួលក្នុងការផ្គត់ផ្គង់ខ្លះ។ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអតិបរមាដល់ការប្រើប្រាស់របស់អតិថិជន អគ្គិសនីកម្ពុជា នឹងធ្វើការសាកល្បងប្រព័ន្ធបរិក្ខារអគ្គិសនីនៅចន្លោះម៉ោង ២៣:០០ ដល់ ២៤:០០ យប់ និងម៉ោង ៥:០០ ដល់ ៦:០០ ព្រឹក ដែលការផ្លាស់ប្តូរម្តងមានការរអាក់រអួល ប្រហែល ៣០ នាទី នៅក្នុងតំបន់មួយចំនួន ដូចខាងក្រោមៈ

១. ចាប់ពីមុខតុលាការកាត់ទោសខ្មែរក្រហមទៅដល់ថ្នល់ទទឹង
២. តាមដងផ្លូវលេខ៥១ចាប់ពីថ្នល់ទទឹងដល់ផ្លូវជាតិលេខ៥
៣. ចាប់ពីម្តុំស្ពានឧកញ៉ាលីយុងផាត់ដល់ព្រែកព្នៅ
៤. ទីរួមខេត្តកំពង់ចាមស្រុកចំការលើ និងស្រុកជើងព្រៃ
៥. តំបន់មួយចំនួនភាគខាងត្បូងខេត្តកំពង់ធំ
៦. តំបន់មួយចំនួននៅក្រុងសួងខេត្តត្បូងឃ្មុំ

ទន្ទឹមនឹងនោះ **អគ្គិសនីកម្ពុជា** នឹងខិតខំបន្ថែមក្នុងកាត់បន្ថយរយៈពេលនៃការរអាក់រអួលការផ្គត់ផ្គង់នេះ ឲ្យបានក្នុងកំរិតអប្បបរមា។

អាស្រ័យហេតុនេះសូមសម្តេចទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**